**លេខៈ** ៣៧ សសរ

# សេចក្តីសំរេច

## ស្តីពី

## ការបង្កើតក្រុមការងារសំរាប់សំរបសំរួលនិងដោះស្រាយ សំណូមពររបស់អាជីវករនៅផ្សារលើ ក្រុងព្រះសីហនុ

### រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

### សំរេច

**ប្រការ១:** ‑ត្រូវបានបង្កើតក្រុមការងារសំរាប់សំរបសំរួល និងដោះស្រាយសំណូមពររបស់អាជីវករនៅផ្សារលើ ក្រុងព្រះសីហនុ ហៅកាត់ថា "ក្រុមការងារ" ។

**ប្រការ២:** ‑ក្រុមការងារមានសមាសភាពដូចខាងក្រោម ៖

| | |
|---|---|
| ‑ឯកឧត្តម ឌឹម រឿន អគ្គលេខាធិការរងរាជរដ្ឋាភិបាលនៃទីស្តីការគណៈរដ្ឋមន្ត្រី | ប្រធាន |
| ‑តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| ‑តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ‑តំណាងសាលាក្រុងព្រះសីហនុ | សមាជិក |
| ‑តំណាងទីស្តីការគណៈរដ្ឋមន្ត្រី | សមាជិក |

**ប្រការ៣:** ក្រុមការងារនេះមានភារកិច្ចដូចតទៅ ៖

‑ពិនិត្យសំណូមពរជាក់ស្តែងរបស់អាជីវករផ្សារលើ

_ប្រមូលពត៌មាន វិភាគពត៌មាន និងវាយតំលៃអំពីស្ថានការណ៍ដែលកើតឡើងទាក់ទងនឹងលក្ខខ័ណ្ឌនៃការធ្វើ អាជីវកម្មផ្សារចាស់( ផ្សារលើ) និងផ្សារថ្មី (មជ្ឈមណ្ឌលពាណិជ្ជកម្មរបស់ក្រុមហ៊ុន វ៉ាយ ជូ ស្ថាបនា អភិវឌ្ឍន៍ ហូលឌីង ចំកាត់)

_រិះរកវិធីសាស្ត្រ មធ្យោបាយ និងវិធានការដែលធានាអោយមានសុវត្ថភាព ប្រក្រតីភាព ស្ថេរភាពអាជីវកម្ម និងការទទួលផលដែលអាចទទួលយកបានដូចៗគ្នារវាងភាគីទាំងឡាយដែលពាក់ព័ន្ធ

_ធ្វើរបាយការណ៍ជូនរាជរដ្ឋាភិបាលអោយបានទាន់ពេល ដើម្បីពិនិត្យដោះស្រាយនូវរាល់ករណីដែលបានកើតឡើង

**ប្រការ៤:** _សមាជិកក្រុមការងារត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៥:** _រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី និងឯកឧត្តមអស់លោកដែលមានឈ្មោះក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៥ ខែ ឧសភា ឆ្នាំ ២០០៤

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

ចម្លងជូន:

_ក្រសួងព្រះបរមរាជវាំង

_អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

_អគ្គលេខាធិការដ្ឋានរដ្ឋសភា

"ដើម្បីជូនជ្រាប"

_ដូចប្រការ ៥ "ដើម្បីអនុវត្ត"

_ឯកសារ_កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:**....០៧......សជណ

# សារជូនពរ

## របស់សម្តេច ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា និង ជាប្រធានកិត្តិយសក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្នុងឱកាស ខួបលើកទី ៥៥ ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ ២០០៤

~~~~~~~~~

-សូមក្រាបថ្វាយបង្គំ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះថេរានុថេរៈគ្រប់ព្រះអង្គ !

-ជនរួមជាតិជាទីស្នេហា !

-ក្មួយៗកុមារា កុមារីជាទីស្រលាញ់ !

នៅក្នុងឱកាសដ៏មហោឡារិកនៃខួបលើកទី៥៥ **ទិវាកុមារអន្តរជាតិ ១ មិថុនា និង ទិវាពិភពលោកប្រឆាំងនឹងពលកម្មកុមារ ១២ មិថុនា ឆ្នាំ២០០៤** នេះ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា និង ក្នុងនាមខ្លួនខ្ញុំព្រះករុណាខ្ញុំផ្ទាល់ សូមសម្តែងនូវក្តីរីករាយជាអតិបរិមាចំពោះ ការប្រារព្ធទិវាដ៏មានសារៈសំខាន់នេះរបស់ក្មួយៗកុមារទាំងអស់ ហើយសូមឱ្យការប្រារព្ធពិធីនេះនៅគ្រប់ទីកន្លែងប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ។

ខ្ញុំសូមសម្តែងនូវការគាំទ្រយ៉ាងពេញទំហឹង ចំពោះសកម្មភាពទាំងឡាយដែលបាន និង កំពុងអនុវត្ត ក្នុងទិសដៅឆ្លើយតបទៅនឹងតម្រូវការចាំបាច់ និងជាមូលដ្ឋានទាំងឡាយរបស់កុមារ ដូចដែលបានចែងក្នុងអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ សំរាប់កុមារកម្ពុជា និង កុមារគ្រប់សញ្ជាតិ គ្រប់ពណ៌សម្បុរ ដែលកំពុងមានវត្តមាននៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា ។

រាជរដ្ឋាភិបាល និង ពលរដ្ឋកម្ពុជាគ្រប់រូប មានកាតព្វកិច្ចធ្វើអោយសុខុមាលភាពរបស់កុមារកាន់តែប្រសើរឡើង ដោយអោយកុមារអាចរស់នៅតាមបញ្ញតិធម្មជាតិ ប្រកបដោយការរីកចំរើនធំធាត់ជាមនុស្សពេញវ័យ មានសុខភាពល្អ បញ្ញាស្មារតីរឹងប៉ឹង មានចំណេះដឹងខ្ពង់ខ្ពស់ [illegible] និង ភាពថ្លៃថ្នូរ ។ ការអភិវឌ្ឍន៍កុមារ និង ការកាត់បន្ថយភាពក្រីក្រ ជាគន្លឹះដ៏មានសារៈសំខាន់បំផុតដើម្បីផ្តល់ឱកាសអោយកុមារ ក្រេបយកចំណេះដឹងទូទៅ បច្ចេកទេសជំនាញទាំងឡាយ ឈានទៅទទួលនូវសិទ្ធិអំណោចខាងផ្នែកសេដ្ឋកិច្ច សង្គម ព្រមទាំងជួយអោយក្មួយៗអាចប្រើប្រាស់
~~~~~~~~~

បានពេញលេញនូវសមត្ថភាពរបស់ខ្លួន ដើម្បីចូលរួមវិភាគទានជាវិជ្ជមាន ក្នុងការអភិវឌ្ឍប្រទេសជាតិលើ គ្រប់វិស័យ ហើយនាំសង្គមជាតិឈានទៅរកវឌ្ឍនភាពដ៏សម្បូររុងរឿង ស្របទៅនឹងសម្ទាក់ភិពពលោកនាពេលអនាគត ។

ដើម្បីសំរេចបាននូវគោលដៅដ៏ឧត្តុង្គឧត្តមនេះ រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តអនុវត្តអោយបានល្អប្រសើរ នូវគោលនយោបាយ ផែនការ និង យុទ្ធសាស្ត្រជាតិ ដោយផ្តោតជាពិសេសលើបញ្ហា៤ជាអាទិភាពគឺ :

- **ការកាត់បន្ថយអត្រាមរណភាពរបស់មាតា និង ទារក** ដោយបង្កើនសេវាថែទាំសុខភាពមាតា និង ទារក
- **ការអប់រំប្រកបដោយគុណភាព និង ការកាត់បន្ថយគម្លាតយេនឌ័រ**
- **ការប្រយុទ្ធនឹងមេរោគអេដស៍ / ជម្ងឺអេដស៍**
- **កិច្ចការពារកុមារ ប្រឆាំងការជួញដូរ ការកេងប្រវ័ញ្ច និង ការរំលោភបំពាន** ពិសេសការរំលោភផ្លូវភេទលើកុមារ ដែលជាការរំលោភសិទ្ធិដ៏ធ្ងន់ធ្ងរ ។

ក្នុងឱកាសដ៏ល្អប្រពៃនេះ ខ្ញុំព្រះករុណាខ្ញុំសូមឧទ្ទិសអោយទិវា ១ មិថុនា និង ១២ មិថុនា ក្លាយទៅជាការប្តេជ្ញាចិត្តជាសកល និង ទៅជាការរំពាវនាវរបស់កុមារដល់គ្រប់ស្ថាប័នជាតិ សហគមន៍ និង ពលរដ្ឋកម្ពុជាគ្រប់រូប សូមផ្តល់ការយកចិត្តទុកដាក់ខ្ពស់ដល់កុមារ ដែលជាសសរទ្រូងរបស់ប្រទេសជាតិ ។

ខ្ញុំព្រះករុណាខ្ញុំ សូមសំដែងនូវការកោតសរសើរដ៏ស្មោះស្ម័គ្រ និង ការវាយតម្លៃខ្ពស់បំផុត ចំពោះទឹកចិត្តស្រលាញ់ ចិញ្ចឹមបីបាច់ថែរក្សា ព្យាបាល អប់រំ បណ្តុះបណ្តាល និង ធ្វើពលិកម្មគ្រប់បែបយ៉ាងដែលប្រកបដោយ ព្រហ្មវិហារធម៌ដ៏ថ្លៃថ្លា របស់មាតាបិតាចំពោះបុត្រធីតា លោកគ្រូអ្នកគ្រូចំពោះសិស្សានុសិស្ស និងសូមកោតសរសើរ ដល់ស្មារតីយកចិត្តទុកដាក់ និង ទទួលខុសត្រូវរបស់មន្ត្រីរាជការ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល ដែលបានបំ ពេញភារកិច្ចលើកស្ទួយដល់សិទ្ធិកុមារ ។ ទន្ទឹមនេះដែរ ខ្ញុំសូមឱ្យក្មួយៗខិតខំប្រឹងប្រែងរៀនសូត្រ និង ថែរក្សាប្រពៃណីខ្មែរ ដើម្បីក្លាយខ្លួនទៅជាកូនល្អ សិស្សល្អ មិត្តល្អ និង ជាពលរដ្ឋល្អក្នុងថ្ងៃអនាគត ។

ជាទីបញ្ចប់ ខ្ញុំព្រះករុណាខ្ញុំ សូមប្រគេនពរដល់ព្រះថេរានុថេរៈគ្រប់ព្រះអង្គ និង ជូនពរចំពោះជនរួមជាតិជាទីស្នេហា ក្មួយៗទាំងអស់ សូមប្រកបដោយសេចក្តីសុខគ្រប់ប្រការ និង មានសិរីសួស្តីដ៏ត្រចះត្រចង់ មានជោគជ័យលើរាល់ភារកិច្ច ជំនះរាល់ការលំបាកដើម្បីបុព្វហេតុជាតិមាតុភូមិ និង បុព្វហេតុរួមរបស់កុមារកម្ពុជា ។

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៤

**ហ៊ុន សែន**

នាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ០៩៩ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ០៧ ខែ ឧសភា ឆ្នាំ ២០០៤

# ប្រកាស

## ស្ដីពី

## ស្ថានភាពរោងចក្រ DONG DA SHOES (CAMBODIA) CO., LTD.

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៩៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១ :** ចាត់ទុកថាបាន **បិទទ្វារជាបណ្ដោះអាសន្ន** រោងចក្រស្បែកជើង **DONG DA SHOES (CAMBODIA) CO., LTD.** ដែលគ្មានសកម្មភាពចំពោះមុខដោយមានមូលហេតុផ្សេងៗ ប៉ុន្តែ [illegible] និង គ្រឿងម៉ាស៊ីននៅក្នុងរោងចក្រ [illegible] បន្ទាប់ពី ការបិទទ្វារជាបណ្ដោះអាសន្ន ។

រោងចក្រស្បែកជើងនេះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅនាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ រោងចក្រខាងលើនេះអាចទទួលបានសិទ្ធនាំចេញសាជាថ្មីប្រសិនបើរោងចក្រនោះបន្តសកម្មភាពរបស់ខ្លួនវិញក្នុងរយៈពេល ៣ ខែបន្ទាប់ ។ ប្រសិនបើរោងចក្រនោះមិនបានបន្តសកម្មភាពរបស់ខ្លួនក្នុងរយៈពេល ៣ ខែបន្ទាប់ រោងចក្រទាំងនោះនឹងត្រូវចាត់ទុកថាបានបិទទ្វារជាស្ថាពរ ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្ម របស់គេនឹងត្រូវលុបពពណ៌ក្រហម និង ចារថាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀត នឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម នាយកដ្ឋាន ពាណិជ្ជកម្មក្រៅប្រទេស នាយកដ្ឋាននីតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតីយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយិកាខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននីតិកម្ម និង រោងចក្រដែលមានឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

<u>ចម្លងជូន :</u>

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
  ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- [illegible]
- [illegible]
- [illegible]
- [illegible]
- [illegible]
- [illegible]

ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. 099 MOC / M 2004

***From the Minister's Desk***

Phnom Penh, May 31 , 2004

## PRAKAS

### On The Status of DONG DA SHOES (CAMBODIA) CO., LTD. in Cambodia

*****

## THE MINISTER OF COMMERCE

- *Pursuant to the Constitution of the Kingdom of Cambodia;*
- *Pursuant to the Preah Reach Kram No 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of Ministers;*
- *Pursuant to the Royal Decree No NS/RK/1198/72 dated November 30, 1998 on the Appointment of the Royal Government of Cambodia;*
- *Pursuant to the Preah Reach Kram No SN/RK/ 0196/16 dated January 24, 1996 on the Creation of the Ministry of Commerce;*
- *Pursuant to the Sub-Decree No 54 AK dated September 22, 1997 on the Organization and Functioning of the Ministry of Commerce;*
- *Seen the needs of the Ministry;*

## DECIDES

**Article 1.** To consider as ***temporarily closed*** the footwear factory of **DONG DA SHOES (CAMBODIA) CO., LTD.,** which was temporarily inactive for various reasons but whose production facilities, equipment and machinery are kept intact and whose workers were temporarily laid off.

This factory would be de-registered from the GSP List of Eligible Exporter at the Trade Preferences Department. The eligibility of the said factory would be restored if it resumes its activities within the next three

months. If it was not resuming its activities in the next three months, it would be considered as definitely closed. Its registration at the Ministry of Commerce's Commercial Register would be then struck in red and annotated as "closed".

**Article 2.** Further investigations shall be undertaken by the Trade Preferences Department, the Foreign Trade Department and the Legal Affairs Department regarding the liabilities and responsibilities of the above said company towards third parties in Cambodia as well as its liabilities vis-à-vis Cambodian laws and regulations.

**Article 3.** The Director of the Minister's Cabinet, the Technical Director General, the Director of the Trade Preferences Department, the Director of the Foreign Trade Department, the Director of the Legal Affairs department and the company whose name appears in Article 1 shall implement this Prakas from the date of its signing.

*The Minister of Commerce*

**CHAM PRASIDH**

CC

Cabinet of H.E. Samdech Prime Minister
Cabinet of H.E. DPM & Co-Minister of Interior
Cabinet of the Council of Ministers
Council for Development of Cambodia (CDC)
Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
EU Delegation in Phnom Penh
Cambodia Shoes Industry Association
Royal Gazette
MOC Archives

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**KINGDOM OF CAMBODIA**

Nation - Religion - King

**ក្រសួងពាណិជ្ជកម្ម**

**Ministry of Commerce**

No. ៤០០ MOC / M 2004

រាជធានីភ្នំពេញ, ថ្ងៃទី ៧៧ ខែ ឧសភា ឆ្នាំ ២០០៤

# <u>ប្រកាស</u>

## ស្តីពី ស្ថានភាពរោងចក្រកាត់ដេរ LARRY GARMENT INC.

*****

## រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យ លេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ ក្រសួងពាណិជ្ជកម្ម
- បានឃើញការចាំបាច់របស់ក្រសួង

# <u>សំរេច</u>

<u>ប្រការ</u> ១ : ចាត់ទុករោងចក្រកាត់ដេរសំលៀកបំពាក់ **LARRY GARMENT INC.** ដែលលែងមានដំណើរការ ហើយកម្មករត្រូវបានបញ្ឈប់ពីការងារ ថាបាន**បិទទ្វារជាស្ថាពរ** : រោងចក្រកាត់ដេរសំលៀកបំពាក់នេះនឹងត្រូវលុបចេញពីតារាង GSP នៃអ្នកមានសិទ្ធនាំចេញនៅ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម ។ ការចុះបញ្ជីពាណិជ្ជកម្មនៅក្រសួងពាណិជ្ជកម្មរបស់គេនឹងត្រូវ ឆូតពណ៌ក្រហម និងគោះជាបានបិទទ្វារ ។

**ប្រការ ២ :** ការស៊ើបអង្កេតបន្ថែមទៀតនឹងត្រូវធ្វើឡើងដោយ នាយកដ្ឋានប្រព័ន្ធអនុគ្រោះពាណិជ្ជកម្ម , នាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , នាយកដ្ឋាននិតិកម្ម ទាក់ទិនបំណុល និង ការទទួលខុសត្រូវផ្សេងៗនៃរោងចក្រដែលមានឈ្មោះខាងលើចំពោះតតិយជននៅកម្ពុជា ព្រមទាំងបំណុលរបស់គេចំពោះច្បាប់ និង បទបញ្ញត្តិកម្ពុជា ។

**ប្រការ ៣ :** នាយិកាខុទ្ទកាល័យ , អគ្គនាយកបច្ចេកទេស , ប្រធាននាយកដ្ឋានប្រព័ន្ធអនុគ្រោះ ពាណិជ្ជកម្ម , ប្រធាននាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស , ប្រធាននាយកដ្ឋាននិតិកម្ម និង រោងចក្រដែលមាន ឈ្មោះក្នុងប្រការ ១ ត្រូវអនុវត្តតាមប្រកាសនេះអោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខា នេះតទៅ ។

**រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

**ចម ប្រសិទ្ធ**

**ចម្លងជូន :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
- ខុទ្ទកាល័យទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវៈនីតិសម្បទា
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស
- ស្ថានរាជទូតកម្ពុជាប្រចាំទីក្រុងវ៉ាស៊ីនតោនឌីស៊ី
- ស្ថានទូតសហរដ្ឋអាមេរិកប្រចាំនៅកម្ពុជា
- គណៈប្រតិភូសហគមន៍អឺរ៉ុបប្រចាំទីក្រុងភ្នំពេញ
- សមាគមកាត់ដេរសំលៀកបំពាក់នៅកម្ពុជា
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

**KINGDOM OF CAMBODIA**

Nation - Religion - King

ក្រសួងពាណិជ្ជកម្ម

**Ministry of Commerce**

No. 100 MOC / M 2004

***From the Minister's Desk***

Phnom Penh, May 31 , 2004

## PRAKAS

### On The Status of LARRY GARMENT INC. in Cambodia

*****

## THE MINISTER OF COMMERCE

- *Pursuant to the Constitution of the Kingdom of Cambodia;*
- *Pursuant to the Preah Reach Kram No 02/NS/94 dated July 20, 1994 on the Organization and Functioning of the Council of Ministers;*
- *Pursuant to the Royal Decree No NS/RK/1198/72 dated November 30, 1998 on the Appointment of the Royal Government of Cambodia;*
- *Pursuant to the Preah Reach Kram No SN/RK/ 0196/16 dated January 24, 1996 on the Creation of the Ministry of Commerce;*
- *Pursuant to the Sub-Decree No 54 AK dated September 22, 1997 on the Organization and Functioning of the Ministry of Commerce;*
- *Seen the needs of the Ministry;*

## DECIDES

**Article 1.** To consider as ***definitely closed*** the garment factory of LARRY GARMENT INC., which ceased to be operational and whose workers are laid off:

This factory shall be de-registered from the GSP List of Eligible Exporters at the Trade Preferences Department. Its registration at the Ministry of Commerce's Commercial Register shall be struck in red and annotated as "closed".

**Article 2.** Further investigations shall be undertaken by the Trade Preferences Department, the Foreign Trade Department and the Legal Affairs Department regarding the liabilities and responsibilities of the above said company towards third parties in Cambodia as well as its liabilities vis-à-vis Cambodian laws and regulations.

**Article 3.** The Director of the Minister's Cabinet, the Technical Director General, the Director of the Trade Preferences Department, the Director of the Foreign Trade Department, the Director of the Legal Affairs department and the company whose name appears in Article 1 shall implement this Prakas from the date of its signing.

*The Minister of Commerce*

**CHAM PRASIDH**

CC:
Cabinet of H.E. Samdech Prime Minister
Cabinet of H.E. DPM & Co-Minister of Interior
Cabinet of the Council of Ministers
Council for Development of Cambodia (CDC)
Ministry of Economy and Finance
Ministry of Industry, Mines and Energy
Ministry of Social Action, Labor, Vocational Training and Youth Rehabilitation
Royal Cambodian Embassy in Paris
Royal Cambodian Embassy in Washington DC
US Embassy in Phnom Penh
EU Delegation in Phnom Penh
Garment manufacturers Association in Cambodia
Royal Gazette
MOC Archives

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ : ១.៧៥៤......សសរ.កសក.ផ.ផក

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារគ្រប់គ្រងដីរដ្ឋ

---

### រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ចុះថ្ងៃទី៣០ ខែវិច្ឆិកាឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០០ ស្តីពី ការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- បានឃើញលិខិតលេខ ១០៩៥ ជនស/កគដ ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ២០០៣ របស់ឧត្តមក្រុមប្រឹក្សាកំណែទំរង់រដ្ឋក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

### សម្រេច

**ប្រការ១:** ត្រូវបានតែងតាំងសមាសភាពក្រុមការងារស្តីពីការគ្រប់គ្រងដីរដ្ឋដែលមានសមាសភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១-លោក **ហុង ណារិត** | អនុប្រធាននាយកដ្ឋានផែនការស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | ប្រធាន |
| ២- លោក **ជី សុចិន្តា** | អនុប្រធានការិយាល័យផែនការ នៃ នាយកដ្ឋានផែនការ ស្ថិតិ និង សហប្រតិបត្តិការអន្តរជាតិ | សមាជិកអចិន្ត្រៃយ៍ |
| ៣- លោក **ស៊ុំ សារឿន** | នាយករងវិទ្យាស្ថានស្រាវជ្រាវកៅស៊ូកម្ពុជា | សមាជិក |
| ៤-លោក **សេង សារ៉ុន** | ប្រធានការិយាល័យគណនេយ្យ នៃនាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ | សមាជិក |
| ៥-លោក **ចាប ចាន់ដារ៉ា** | អនុប្រធានការិយាល័យផែនការ គណនេយ្យ នៃនាយកដ្ឋានជលផល | សមាជិក |

| | | |
|---|---|---|
| ៦-លោក **ម៉ៅ សុទណ្ឌារី** | អនុប្រធានការិយាល័យទទួលពាក្យបណ្តឹងនៃអគ្គាធិការដ្ឋាន | សមាជិក |
| ៧-លោក **ហូ ពុទ្ធា** | អនុប្រធានការិយាល័យបច្ចេកទេស នៃនាយកដ្ឋានក្សេត្រសាស្ត្រ និង កែលំអដីកសិកម្ម | សមាជិក |
| ៨-លោក **នួច ម៉ុនឆៀង** | អនុប្រធានការិយាល័យ អភិវឌ្ឍន៍កសិ-ឧស្សាហកម្ម នៃនាយកដ្ឋានកសិ-ឧស្សាហកម្ម | សមាជិក |
| ៩-លោក **ស៊ាន គុសល** | អនុប្រធានការិយាល័យផែនការ-គណនេយ្យ នៃនាយកដ្ឋានផលិតកម្ម និង បសុព្យាបាល | សមាជិក |
| ១០-លោក **ឆៀង សុខុម** | មន្ត្រីរដ្ឋបាលព្រៃឈើ | សមាជិក |
| ១១-លោក **តាន់ សុវណ្ណរត្ន័** | មន្ត្រីនាយកដ្ឋានបច្ចេកទេសនៃអគ្គនាយកដ្ឋានចំការកៅស៊ូ | សមាជិក |
| ១២-លោក **សៅ រ៉ា** | មន្ត្រីការិយាល័យនីតិកម្ម និងផ្សព្វផ្សាយច្បាប់កសិកម្ម នៃនាយកដ្ឋាន និតិកម្មកសិកម្ម | សមាជិក |
| ១៣- លោក **ហ៊ិន សារិត** | មន្ត្រីវិទ្យាស្ថាន ស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា | សមាជិក |

**ប្រការ២:** ក្រុមការងារនេះមានភារកិច្ចរៀបចំចងក្រងប្រមូលផ្តុំទិន្នន័យស្ថិតិស្តីពីការប្រើប្រាស់និងគ្រប់គ្រងដីរដ្ឋធ្វើអត្ថសញ្ញាណកម្ម ធ្វើផែនទី និងចំណោត់ថ្នាក់ដី និងសម្របសម្រួលការផ្តល់ពត៌មាន ។

**ប្រការ៣:** សមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធានក្រុមការងារ ។

**ប្រការ៤:** អគ្គនាយកនៃក្រសួង អគ្គាធិការដ្ឋាន នាយកខុទ្ទកាល័យ ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទនិង អស់លោកដូចមានរាយនាម ក្នុងប្រការ១ ត្រូវទទួលបន្ទុកអនុវត្តតាមសេចក្តីសម្រេច នេះអោយមាន ប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០៤

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
- ឧត្តមក្រុមប្រឹក្សាកំណែទម្រង់ ក្រុមប្រឹក្សាគោលនយោបាយដីធ្លី
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងផែនការ
- ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់

“ដើម្បីជូនជ្រាប”

- គ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត-ក្រុង

“ដើម្បីសហការ”

- ដូចប្រការ ៤ “ដើម្បីអនុវត្ត”
- ឯកសារ- កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា

### ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងទេសចរណ៍

លេខ: ៤៩ ទ.ក

ភ្នំពេញ ថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០៤

## ប្រកាស

### ស្តីពីការបង្កើតក្រុមការងារសិក្សាស្រាវជ្រាវអំពីគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ

ៜៜៜៜៜ

### ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត.១១៩៨.៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២.នស.៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើប្រាស់ច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស.រកម.០១៩៦.១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ៣៤ អនក្រ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងទេសចរណ៍
- បានឃើញអនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែឧសភា ឆ្នាំ ២០០០ ស្តីពីការកែសំរួលមុខងារ និងភារកិច្ច និងការបង្កើតក្រុមអ្នកច្បាប់ និងនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងអាស៊ាន នៃក្រសួងទេសចរណ៍
- យោងលិខិតលេខ ៨០៥ អស១.កបទ.សអ ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ ២០០២ របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- អនុក្រឹត្យលេខ៣៥ អនក្រ.បក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០២ របស់រាជរដ្ឋាភិបាលកម្ពុជា ស្តីពីការបង្កើតគណៈកម្មការសហប្រតិបត្តិការអនុវត្តតំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ
- យោងតំរូវការចាំបាច់របស់ក្រសួងទេសចរណ៍

### សំរេច

**ប្រការ១** : បង្កើតក្រុមការងារគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ ។

**ប្រការ២** : ក្រុមការងារគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និងកម្ពុជា-ឡាវ-ថៃ ដែលមានសមាជិកភាពដូចខាងក្រោម :

| | | |
|---|---|---|
| ១- លោក ទិត ចន្ថា | អគ្គនាយករងទេសចរណ៍ | ប្រធាន |
| ២- លោក រស់ សំអ៊ា | ប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | អនុប្រធានអចិន្ត្រៃយ៍ |
| ៣- លោក ម៉ី ម៉ារ៉ាឌី | ប្រធាននាយកដ្ឋានស្ថិតិ និងពតិមានទេសចរណ៍ | សមាជិក |
| ៤- លោក អ៊ុំ ឃីម | អនុប្រធាននាយកដ្ឋានឧស្សាហកម្មទេសចរណ៍ | សមាជិក |
| ៥- លោក សុខ សុគុណ | អនុប្រធាននាយកដ្ឋានផែនការអភិវឌ្ឍន៍ | សមាជិក |
| ៦- លោក ជុំ សារិដ្ឋ | អនុប្រធាននាយកដ្ឋានអភិវឌ្ឍន៍ទេសចរណ៍វប្បធម៌ | សមាជិក |
| ៧- លោក ផ្លង ធឿន | អនុប្រធាននាយកដ្ឋានសិក្សាទីផ្សារ និងផ្សព្វផ្សាយ | សមាជិក |
| ៨- លោក យិន ណាត | នាយការិយាល័យមេគង្គ (GMS) | សមាជិក |

**ប្រការ៣** : ក្រុមការងារនេះមានភារកិច្ចដូចខាងក្រោម :

- រៀបចំផែនការការងារ កិច្ចប្រជុំ និងរបៀបវារៈនៃអង្គប្រជុំ របស់ក្រុមការងារនេះឆ្លងថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។
- ចូលរួមប្រជុំ និងធ្វើរបាយការណ៍ ជូនគណៈកម្មការសហប្រតិបត្តិការ អភិវឌ្ឍន៍តំបន់ត្រីកោណ កម្ពុជា-វៀតណាម-ឡាវ និង កម្ពុជា-ឡាវ-ថៃ ។
- សំរបសំរួល និងទំនាក់ទំនងការងារជាមួយបណ្តាក្រសួង-ខេត្ត និងអង្គការអន្តរជាតិនានា ដើម្បីគោលបំណងអភិវឌ្ឍន៍តំបន់ត្រីកោណ ។
- រៀបចំគំរោងអភិវឌ្ឍន៍ទេសចរណ៍តំបន់ត្រីកោណទាំងពីរ ដោយធ្វើទំនាក់ទំនងជាមួយស្ថាប័នជាតិ និងអន្តរជាតិនានា សិក្សាគ្រប់លទ្ធភាពស្វែងរកប្រភពហិរញ្ញវត្ថុដើម្បីជួយដល់ការងារអភិវឌ្ឍន៍នេះ ។
- សមាជិកក្រុមការងារនេះត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន ហើយបើចាំបាច់អាចមានសិទ្ធិអញ្ជើញមន្ត្រីជំនាញនាយកដ្ឋានផ្សេងទៀតចូលរួមដោយសុំយោបល់ថ្នាក់ដឹកនាំក្រសួងពិនិត្យ និងសំរេច ។

**ប្រការ៤** : នាយកខុទ្ទកាល័យ អគ្គនាយកទេសចរណ៍ អគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ អធិការ ប្រធានគ្រប់ នាយកដ្ឋាន និងសមាជិកក្រុមការងារនេះត្រូវទទួលអនុវត្តនូវប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទេសចរណ៍**

**វង្ស សិរីវុឌ្ឍ**

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- ក្រសួងពាណិជ្ជកម្ម
  "ដើម្បីជូនជ្រាប"
- ដូចក្នុងប្រការ២ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់

លេខ.- ០៤២...ដនស/សជ

ភ្នំពេញ, ថ្ងៃទី២៦ ខែ ឧសភា ឆ្នាំ ២០០៤

# សេចក្តីណែនាំស្តីពីការចុះបញ្ជីដីបន្ត

រយៈកន្លងមកឯកសារសុរិយោដីត្រូវបានកសាង និងកាន់កាប់តាមពីររបៀប គឺរបៀបចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងរបៀបចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ។ ឯកសារមូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មានទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី បញ្ជីឈ្មោះម្ចាស់ដី ប្លង់សុរិយោដី និងឯកសារណាបផ្សេងៗ ។ រីឯឯកសារមូលដ្ឋាននៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ មានពាក្យស្នើសុំកាន់កាប់ ប្រើប្រាស់ដីធ្លី, ប្រកាសជូនដំណឹងពីការចុះធ្វើអង្កេត វាស់វែង, កំណត់ហេតុអង្កេតដី និងឯកសារណាបផ្សេងៗ ។

ឯកសារទាំងនោះ ទោះបីមានការណែនាំជាបន្តបន្ទាប់ក៏ដោយ ក្រសួងសង្កេតឃើញថា ការកាន់កាប់ឯកសារសុរិយោដី នៅមិនទាន់ឯកភាពគ្នា និងមានភាពសុក្រឹតនៅឡើយ។

ដើម្បីឱ្យមានភាពរលូនក្នុងការងារ ពិសេសពាក់ព័ន្ធនឹងការងារចុះបញ្ជីដីបន្ត ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សូមធ្វើការណែនាំដល់គ្រប់មន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដូចតទៅ :

- ត្រូវបន្តពង្រឹង ណែនាំដល់មន្ត្រីក្រោមឱវាទ ជាអាទិ៍ ថ្នាក់ដឹកនាំការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ មន្ត្រីទទួលបន្ទុកកាន់កាប់ឯកសារ (មន្ត្រីអភិរក្សសុរិយោដី)ឱ្យខិតខំយកចិត្តទុកដាក់ បង្កើនស្មារតីទទួលខុសត្រូវខ្ពស់ក្នុងការកសាងឯកសារមូលដ្ឋាន ដូចជាកិច្ចសន្យាលក់ លិខិតអំណោយផ្ដាច់ ការបញ្ជាក់អំពីប្រភេទទ្រព្យ ការបញ្ជាក់អំពីអត្តសញ្ញាណម្ចាស់ទ្រព្យ និងកិច្ចសន្យាដាក់បន្ទុកលើអចលនវត្ថុជាដើម ធ្វើការផ្ទៀងផ្ទាត់ ត្រួតពិនិត្យសុពលភាព ភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារ ។

អាសយដ្ឋាន : លេខ ៧៧១-៧៧៣ មហាវិថី ព្រះមុនីវង្ស សង្កាត់ បឹងត្របែក ខណ្ឌ ចំការមន ក្រុងភ្នំពេញ
Tel/Fax : (855-23) 215 660, e-mail : mlmup...

• ត្រូវបន្តពង្រឹងការកាន់កាប់ឯកសារមូលដ្ឋាន ដោយត្រូវធ្វើបន្តការក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី ផែនទីមានលក្ខណៈដាច់ដោយដុំ និងប្លង់សុរិយោដី នូវរាល់ការប្រែប្រួលគតិយុត្ត ឬលក្ខណៈរូបនៃក្បាលដី កសាងតារាងរាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ(T.A=Tableau Alphabétique des propriétaires) ពង្រឹងការងារប័ណ្ណសារដ្ឋាន...។

• ត្រូវយកចិត្តទុកដាក់សំរបសំរួលគ្នារវាងការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ និងការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ដោយ :

-ចំពោះ**ការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ** ត្រូវប្រមូលប័ណ្ណចាស់(ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ប្រើប្រាស់ដីធ្លី ឬប័ណ្ណស្នាមមាន់ ចេញដោយអតីតការិយាល័យសុរិយោដីខេត្ត ក្រុង ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុចេញដោយអតីតនាយកដ្ឋានសុរិយោដី ឬអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ) ដែលបានចេញហើយក្នុងតំបន់ធ្វើការវិនិច្ឆ័យ នៅពេលចែកវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ រួចធ្វើតារាង(គំរូលេខ ១)ផ្ញើជូននាយកដ្ឋានអភិរក្សដើម្បីចាត់ការតាមនីតិវិធីអភិរក្សសុរិយោដី។

ម្យ៉ាងទៀត ចំពោះវិញ្ញាបនប័ត្រគំរូចាស់ដែលបានចេញរួចកន្លងមក នៅពេលមានការផ្លាស់ប្តូរ ប្រែប្រួលសិទ្ធិ ឬលក្ខណៈរូបនៃក្បាលដី ត្រូវប្រមូលមកវិញ ហើយចេញវិញ្ញា-បនប័ត្រគំរូថ្មីជំនួសវិញ ។ ឯវិញ្ញាបនប័ត្រចាស់ ត្រូវគូសឆូត ឬបោះត្រាមោឃភាព ហើយរក្សាទុកជាឯកសារ រួចធ្វើតារាងសម្រង់អចលនវត្ថុផ្ញើជូននាយកដ្ឋានអភិរក្សសុរិយោដី ផ្នែកប្រព័ន្ធព័ត៌មានដី(LIS) នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ ដើម្បីធ្វើបន្តការក្នុងឯកសារសុរិយោដីឱ្យបានស្របគ្នា ។

បន្ទាប់ពីសេចក្តីណែនាំនេះត្រូវបានសំរេចហើយ ផ្នែកប្រព័ន្ធព័ត៌មានដី(LIS) និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ត្រូវផ្ញើឯកសារសុរិយោដីនៃតំបន់ចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធទាំងអស់ មានប្លង់សុរិយោដី សៀវភៅគោលបញ្ជីដី បញ្ជីឈ្មោះម្ចាស់ដី ទៅនាយកដ្ឋានអភិរក្សសុរិយោដី ដើម្បីតាមដានការវិវត្តន៍នៃក្បាលដី ត្រួតពិនិត្យការធ្វើលេខាចារឹកលើឯកសារ ផងជាមូលដ្ឋានក្នុងការផ្តល់ព័ត៌មានដល់ជនទាំងឡាយដែលបានមកទាក់ទងសាកសួរ ។

-ចំពោះ**ការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ** បន្ទាប់ពីទទួលបានឯកសារ នាយក-ដ្ឋានអភិរក្ស ត្រូវចាត់ធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងរាយឈ្មោះ

ម្ចាស់ដីតាមលំដាប់អក្សរ រួចធ្វើតារាងសម្រង់អចលនវត្ថុផ្ញើជូនផ្នែកប្រព័ន្ធព័ត៌មានដី(LIS) នៃអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីធ្វើបន្តការឱ្យបានស្របគ្នា ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងតារាងរាយឈ្មោះម្ចាស់ដីតាមលំដាប់អក្សរ ។

**I.-នីតិការកសាងឯកសារ ..**

• **ការចុះបញ្ជីដីបន្តទាក់ទងនឹងការផ្ទេរសិទ្ធិ :** ក្នុងរឿងអចលនវត្ថុ ការផ្ទេរសិទ្ធិអាចប្រព្រឹត្តទៅបាន ហើយតតីយជនមិនអាចជំទាស់បាន លុះត្រាតែលិខិតផ្ទេរសិទ្ធិនោះធ្វើឡើងតាមរូបមន្តយថាភូត ដោយបុគ្គលដែលមាននីតិសម្បទា និងត្រូវបានចុះបញ្ជីនៅអង្គភាពសុរិយោដី ។ កិច្ចសន្យាដែលនាំទៅដល់ការផ្ទេរសិទ្ធិមាន កិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាឱ្យ និងកិច្ចសន្យាជិះមរតក ។

ក្នុងការតាក់តែងលិខិតសញ្ញាខាងលើ មន្ត្រីទទួលបន្ទុក(ប្រធានការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ)ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវចំពោះមុខច្បាប់លើអត្តសញ្ញាណគូភាគី គឺភាគីអ្នកលក់ ត្រូវតែជាម្ចាស់អចលនវត្ថុដែលត្រូវលក់ពិតប្រាកដ ឬតំណាងស្របច្បាប់របស់ជននេះ ហើយភាគីអ្នកទិញ ត្រូវមានសញ្ជាតិជាខ្មែរ និងមានសមត្ថភាពចុះកិច្ចសន្យា ។

ចំពោះអគារសហកម្មសិទ្ធិ(Condominium) សហកម្មសិទ្ធិករម្នាក់ៗ អាចធ្វើការផ្ទេរសិទ្ធិ បង្កើតសិទ្ធិ ឬកែប្រែសិទ្ធិលើចំណែកឯកជនរបស់ខ្លួនបានដោយសេរី លើកលែងតែការបង្កើតសេវភាព ហើយម្ចាស់បំណុលរបស់គេម្នាក់ៗ អាចប្តឹងរឹបអូសចំណែកឯកជននោះបាន ។

ក្រៅពីកិច្ចសន្យា សេចក្តីសំរេចរបស់តុលាការ ក៏នាំឱ្យទៅដល់ការផ្ទេរសិទ្ធិដែរ ។

• **ការចុះបញ្ជីដីបន្តទាក់ទងនឹងការបង្កើតសិទ្ធិថ្មីលើក្បាលដី:** កិច្ចសន្យាបង្កើតសិទ្ធិថ្មីលើក្បាលដី(ដាក់បន្ទុក ឬធានាសងបំណុល)មាន កិច្ចសន្យាផលុបភោគ, កិច្ចសន្យាបង្កើតសេវភាព, កិច្ចសន្យាបង្កើតសិទ្ធិប្រើប្រាស់ និងអាស្រ័យនៅ, កិច្ចសន្យាហ៊ីប៉ូតែក, កិច្ចសន្យាបញ្ចាំអចលនវត្ថុ, កិច្ចសន្យាដាក់ធានា និងកិច្ចសន្យាជួលរយៈពេលវែង ។ កិច្ចសន្យាទាំងនេះ មិននាំឱ្យទៅដល់ការផ្ទេរសិទ្ធិឡើយ ។

មន្ត្រីទទួលបន្ទុក បន្ទាប់ពីពិនិត្យឃើញថាឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ ត្រូវ

ធ្វើលេខាចារឹកនៅក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី និងចុះបរន្តការក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬក្នុងវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ តាមរូបមន្តកំណត់ ។

• ការចុះបញ្ជីដីបន្តទាក់ទងនឹងការប្រែប្រួលលក្ខណៈរូបនៃក្បាលដី : ការប្រែប្រួលលក្ខណៈរូបនៃក្បាលដី អាចកើតឡើងដោយការព្រមព្រៀងខាងឆន្ទៈ ឬដោយសេចក្ដីសំរេចរបស់តុលាការ ឬដោយធម្មជាតិ ។

មន្ត្រីទទួលបន្ទុកអនុវត្ត ត្រូវយកចិត្តទុកដាក់ និងទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងការវាស់វែង និងការកសាងឯកសារ(សលាកប័ត្របំបែកក្បាលដី, សលាកប័ត្របង្រួមក្បាលដី) ។ លើការងារវាស់វែង ត្រូវយកចិត្តទុកដាក់លើភាពទៀងទាត់ និងច្បាប់ ឬលិខិតបទដ្ឋានគតិយុត្តផ្សេងៗ ដូចជាការកំណត់ចំណីផ្លូវ ការបំរុងទុក ការហាមឃាត់ ជាដើម ។ លើការងារកសាងឯកសារ ត្រូវប្រុងប្រយ័ត្នអំពីអត្តសញ្ញាណម្ចាស់ក្បាលដីជាប់ព្រំ ដែលត្រូវផ្តិតមេដៃឯកភាពអំពីព្រំដីលើឯកសារ ។

បន្ទាប់ពីពិនិត្យឃើញថាឯកសារត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ មន្ត្រីទទួលបន្ទុក ត្រូវធ្វើលេខាចារឹកក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ឬសៀវភៅគោលបញ្ជីដី និងក្នុងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ ។ ដោយឡែក ចំពោះវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ដែលបានចេញក្នុងតំបន់ធ្វើការវិនិច្ឆ័យ ត្រូវប្រមូលវិញ្ញាបនប័ត្រចាស់ រួចចេញវិញ្ញាបនប័ត្រថ្មីជូនម្ចាស់កម្មសិទ្ធិនៃក្បាលដី ដែលត្រូវបានបំបែក ឬបង្រួម វិញ ។

## II.-**អំពីការកាន់កាប់ឯកសារសុរិយោដី** ..

ឯកសារសុរិយោដីរួមមាន ប្លង់សុរិយោដី(Cadastral Index Map) ផែនទីមានលក្ខណៈដាច់ដោយដុំ(Sporadic Index Map) សៀវភៅគោលបញ្ជីដី សៀវភៅចុះបញ្ជីអចលនវត្ថុ និងឯកសាររណប ។

១.-ប្លង់សុរិយោដី គឺជាប្លង់រួមនៃក្បាលដីទាំងឡាយក្នុងតំបន់ធ្វើការវិនិច្ឆ័យដែលបង្ហាញអំពីស្ថានភាពឋានលេខា (Situation topographique) នៃក្បាលដី : រូបសណ្ឋានដី ទីតាំងដី ព្រំប្រទល់ដី ប្រភេទដី និងអ្វីៗដែលមានលើដី ដូចជាសំណង់ ផ្លូវ អណ្តូងទឹក...។ ក្នុងប្រព័ន្ធសុរិយោដីទំនើប(Cadastre informatisé) ប្លង់សុរិយោដីបង្ហាញតាំងពីអ្វីៗនៅក្រោមដី

ទៀត ដូចជា ប្រព័ន្ធលូ ប្រព័ន្ធខ្សែភ្លើង បណ្ដាញឧស្ម័ន បណ្ដាញទូរគមនាគមន៍... ។ ប្លង់សុរិយោដី គ្របដណ្ដប់តំបន់ដែលបានធ្វើការវិនិច្ឆ័យ ដោយមានកំណត់ព្រំប្រទល់កម្មសិទ្ធិសាធារណៈ ឬ/និងកម្មសិទ្ធិឯកជនទាំងអស់ ហើយមានបញ្ជាក់អំពីប្រភេទដី ដូចជា ដីផាំដុះ ដីព្រៃ ដីលិចទឹក ដីសំរាប់សំណង់ឧស្សាហកម្មជាដើម ។ ការកសាងប្លង់សុរិយោដីត្រូវអនុវត្តតាមនីតិវិធីដែលត្រូវចែងក្នុងអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃ ៣១ ឧសភា ២០០២ ស្ដីពីនីតិវិធី នៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី ។

មន្ត្រីទទួលបន្ទុកកាន់កាប់ប្លង់សុរិយោដី ត្រូវតែជាមន្ត្រីជំនាញ ហើយទទួលខុសត្រូវក្នុងការធ្វើបន្ទុកការនូវរាល់ការផ្លាស់ប្ដូរ ប្រែប្រួលទ្រង់ទ្រាយនៃក្បាលដី ដែលបណ្ដាលមកពីការបំបែកក្បាលដី ការបង្រួមក្បាលដី ដោយការព្រមព្រៀង ឬដោយសេចក្ដីសំរេចរបស់តុលាការ ឬដោយតម្រូវការនៃប្រយោជន៍សាធារណៈ ឬដោយធម្មជាតិ (គំរូលេខ ២)។

**ក.-ការប្រែប្រួលដោយការបំបែកក្បាលដី** : បន្ទាប់ពីឯកសារនៃការបំបែកក្បាលដីត្រូវបានសំរេចហើយ លេខក្បាលដីដើមក្នុងប្លង់សុរិយោដី ត្រូវឆូតលុប ហើយដាក់លេខថ្មី។ លេខថ្មី គឺជាលេខបន្តពីលេខចុងក្រោយបង្អស់ នៃក្បាលដីក្នុងភូមិនីមួយៗ ។

**ខ.-ការប្រែប្រួលដោយការបង្រួមក្បាលដី** : ដូចគ្នានឹងចំណុច(ក)ដែរ បន្ទាប់ពីឯកសារនៃការបង្រួមក្បាលដី ត្រូវបានសំរេចហើយ លេខក្បាលដីទាំងឡាយដែលត្រូវបានបង្រួម ត្រូវឆូតលុប ហើយជំនួសវិញដោយលេខថ្មី ដែលជាលេខចុងក្រោយបង្អស់នៃក្បាលដីក្នុងភូមិ ។

**គ.-ការប្រែប្រួលដោយធម្មជាតិ** : ទ្រង់ទ្រាយនៃក្បាលដី អាចប្រែប្រួលដោយធម្មជាតិ ពិសេសចំពោះក្បាលដី ដែលស្ថិតនៅជាប់មាត់ទឹកទន្លេ ស្ទឹង ឬព្រែក ។ ការប្រែប្រួលនេះ អាចថយទំហំ(ករណីដីបាក់) និងអាចកើនទំហំ (ករណីដីដុះ) ។

លេខក្បាលដី ទាក់ទងគ្នានឹងទំហំដី មានន័យថា បើប្រែប្រួលទំហំ គឺមិនមែនក្បាលដីលេខហ្នឹងទេ នោះគឺក្បាលដីថ្មី ដូច្នេះ ត្រូវឆូតលុបលេខក្បាលដីចាស់ ហើយដាក់លេខថ្មីជំនួសវិញ ដូចករណីបំបែក ឬបង្រួមក្បាលដី ។

២.-ផែនទីមានលក្ខណៈដាច់ដោយដុំ : គឺជាប្លង់សុរិយោដី ដែលកសាងឡើងតាមនីតិ-

វិធីនៃការចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ អនុលោមតាមអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ។ មន្ត្រីទទួលបន្ទុក ត្រូវធ្វើបវន្តការ នូវរាល់ក្បាលដីស្នើសុំចុះបញ្ជីដែលបានបិទផ្សាយរួច និងគ្មានការជំទាស់ណាៗ ឬបន្ទាប់ពីបានសម្រុះសម្រួលដោះស្រាយរួច ឬបានដោះស្រាយរួចដោយគណៈកម្មការសុរិយោដីថ្នាក់ជាតិ ។ ការកសាងផែនទីមានលក្ខណៈដាច់ដោយដុំ និងការធ្វើបវន្តការលើផែនទីនេះត្រូវបញ្ជាក់ឱ្យច្បាស់នូវសញ្ញាសំគាល់ចំពោះក្បាលដី(គំរូលេខ ៣) ។

ក្នុងការធ្វើបវន្តការលើផែនទីមានលក្ខណៈដាច់ដោយដុំ មន្ត្រីទទួលបន្ទុក ត្រូវគោរពតាមស្តង់ដារបច្ចេកទេស អំពីមាត្រដ្ឋាន និងភាពទៀងទាត់ ។

៣.-សៀវភៅគោលបញ្ជីដី : សៀវភៅគោលបញ្ជីដី គឺជាសៀវភៅផ្លូវការ មានតម្លៃពេញលេញតាមផ្លូវច្បាប់ ប្រើសំរាប់កត់ត្រានូវសិទ្ធិកម្មសិទ្ធិ និងរាល់ព័ត៌មានទាក់ទងនឹងអត្ត-សញ្ញាណក្បាលដីនីមួយៗ(លេខក្បាលដី, ទីតាំងដី, រូបសណ្ឋាន និងលក្ខណៈប្រើប្រាស់ដី...) អត្តសញ្ញាណម្ចាស់(ឈ្មោះ, ឆ្នាំ និងទីកន្លែងកំណើត, សាវតារ, អាសយដ្ឋាន...) ប្រភេទទ្រព្យ ប្រភព និងបន្ទុកលើក្បាលដី ។

អាស្រ័យដោយបច្ចុប្បន្ន នៅប្រទេសកម្ពុជាយើង មិនទាន់មានបណ្តាញកុំព្យូទ័រ (Computer Network) ភ្ជាប់ដល់មូលដ្ឋាន ការធ្វើលេខាចារឹក និងការចុះបវន្តការក្នុងសៀវភៅគោលបញ្ជីដី ក៏ដូចជាលើប្លង់សុរិយោដី ធ្វើឡើងតាមវិធីកត់ត្រាដោយដៃ ។ ការធ្វើលេខាចារឹក និងការចុះបវន្តការនេះ ត្រូវធ្វើឡើងឱ្យស្របគ្នានៅគ្រប់ថ្នាក់ ក្រោមការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ នៃថ្នាក់នីមួយៗ ។

មានតែមន្ត្រីទទួលបន្ទុកការងាររអភិរក្សប៉ុណ្ណោះ ដែលមានសមត្ថកិច្ចកាន់កាប់ ធ្វើលេខាចារឹក និងចុះបវន្តការក្នុងសៀវភៅគោលបញ្ជីដី លើផែនទីមានលក្ខណៈដាច់ដោយដុំ និងលើប្លង់សុរិយោដី ។ ការសាកសួរព័ត៌មាន ការពិនិត្យមើលទិន្នន័យក្នុងសៀវភៅគោលបញ្ជីដី ត្រូវធ្វើឡើងក្រោមការទទួលខុសត្រូវរបស់មន្ត្រីទទួលបន្ទុក នៅក្នុងការិយាល័យ មិនអនុញ្ញាតឱ្យយកសៀវភៅគោលបញ្ជីដីចេញពីការិយាល័យ ដោយគ្មានការយល់ព្រមពីថ្នាក់ដឹកនាំ បានឡើយ ។

ដោយឡែក ចំពោះប្រព័ន្ធព័ត៌មានដីធ្លី(LIS) នៅថ្នាក់កណ្តាល និងនៅថ្នាក់ខេត្ត ក្រុង

ដែលបានទទួលប្រតិភូកម្មពីក្រសួង ដែលរួមមានប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដី ត្រូវធ្វើឱ្យទាន់សម័យ(Update)ក្នុងកុំព្យូទ័រ នូវទិន្នន័យពីការប្រែប្រួល ផ្លាស់ប្តូរ បន្ទាប់ពីបាន ទទួលតារាងផ្លាស់ប្តូរ ។ ការធ្វើឱ្យទាន់សម័យ(Update)ក្នុងកុំព្យូទ័រនេះ ក៏ត្រូវឱ្យបានស្រប គ្នាដែរ រវាងថ្នាក់កណ្តាល និងថ្នាក់ខេត្ត ក្រុង ដោយត្រូវផ្តល់ព័ត៌មានពីការប្រែប្រួលទិន្ន-ន័យ ទៅវិញទៅមក ក្រោមការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំ នៃថ្នាក់នីមួយៗ ។

របៀបរបបនៃការធ្វើឱ្យទាន់សម័យ(Update) នៃទិន្នន័យក្នុងកុំព្យូទ័រ ត្រូវធ្វើឡើងនៅ ពេលដែលពិនិត្យឃើញថាឯកសារណាបត្រឹមត្រូវ និងគ្រប់គ្រាន់ហើយ រួចបោះពុម្ព( Print) សិរង់ ទើបចុះបន្តការដោយដៃក្នុងសៀវភៅគោលបញ្ជីដី និងប័ណ្ណ។

៤.-សៀវភៅចុះបញ្ជីអចលនវត្ថុ : សៀវភៅចុះបញ្ជីអចលនវត្ថុ គឺជាសៀវភៅផ្លូវការ មានតម្លៃពេញលេញតាមផ្លូវច្បាប់ ប្រើសំរាប់កត់ត្រានូវសិទ្ធិភោគៈ និងរាល់ព័ត៌មានទាក់ទង នឹងអត្តសញ្ញាណក្បាលដីនីមួយៗ(លេខក្បាលដី, ទីតាំងដី, រូបភាព និងលក្ខណៈប្រើប្រាស់ ដី...) អត្តសញ្ញាណម្ចាស់(ឈ្មោះ, ឆ្នាំ និងទីកន្លែងកំណើត, សាវតារ, អាសយដ្ឋាន...) ប្រភេទទ្រព្យ ប្រភព និងបន្ទុកលើក្បាលដី ដូចសៀវភៅគោលបញ្ជីដី ដែរ។

ការកាន់កាប់ ការធ្វើលេខាចារឹក និងការចុះបន្តការក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ ត្រូវធ្វើឡើងតាមរបៀបរបប ដូចគ្នានឹងក្នុងសៀវភៅគោលបញ្ជីដី ដែរ ។

រាល់ការផ្លាស់ប្តូរសិទ្ធិពីភោគៈក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ មកកម្មសិទ្ធិដោយលក្ខ-ខណ្ឌរយៈពេលកាន់កាប់ ៥ឆ្នាំ ត្រូវបានបំពេញ និងត្រឹមដីមាននិយាមកាច្បាស់លាស់ ឬ ដោយតំបន់ដែលក្បាលដីភោគៈនោះ ត្រូវបានធ្វើការវិនិច្ឆ័យ និងបិទផ្សាយជាសាធារណៈរួច អនុលោមតាមអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ ២០០២ ក្បាលដីភោគៈនោះ នឹងត្រូវផ្ទេរមកកត់ត្រាចូលក្នុងសៀវភៅគោលបញ្ជីដីវិញ ។

ម្យ៉ាងទៀត ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី ប្រធានមន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ត្រូវសហការបិទបញ្ជីក្នុងសៀវភៅចុះបញ្ជីអចល នវត្ថុ ក្នុងតំបន់ដែលបានចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធរួច ដោយត្រូវ :

• បើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ បានធ្វើរួចទាំងឃុំ មានន័យថាក្បាលដីទាំង អស់ក្នុងគ្រប់ភូមិនៃឃុំ ត្រូវបានចុះបញ្ជីហើយ ត្រូវធ្វើការផ្ទៀងផ្ទាត់ ធ្វើអត្តសញ្ញាណក្បាលដី ឈ្មោះម្ចាស់ដី លេខប័ណ្ណ ក្នុងសៀវភៅចុះបញ្ជីអចលនវត្ថុ និងធ្វើការកត់ត្រាបញ្ជូនទៅលេខ

សៀវភៅគោលបញ្ជីដី និងលេខក្បាលដី ។ ចំពោះសៀវភៅគោលបញ្ជីដី ក៏ត្រូវកត់ត្រាលេខក្បាលដី(លេខអាទិសង្កេត) ដែលក្បាលដីនោះត្រូវបានប្រើលេខថ្មីតាមប្រព័ន្ធ UPRN ។ ករណីនេះ សៀវភៅចុះបញ្ជីអចលនវត្ថុ ត្រូវបានបញ្ឈប់ ដោយទិន្នន័យទាំងអស់ក្នុងសៀវភៅនេះ ត្រូវបានផ្ទេរទៅសៀវភៅគោលបញ្ជីដីវិញ ។

• បើការចុះបញ្ជីដីមានលក្ខណៈជាប្រព័ន្ធ មិនទាន់បានធ្វើរួចទាំងឃុំ មានន័យថាក្បាលដីមួយចំនួនក្នុងភូមិនៃឃុំ មិនទាន់ត្រូវបានចុះបញ្ជី នោះសៀវភៅចុះបញ្ជីអចលនវត្ថុ ត្រូវបានបន្តប្រើចំពោះតែភូមិណាដែលក្បាលដី មិនទាន់បានចុះបញ្ជីមានលក្ខណៈជាប្រព័ន្ធ ។

៥.-ឯកសារវណាប :

**ក.-លិខិតសញ្ញាទាក់ទងនឹងការផ្ទេរសិទ្ធិ** ដែលរួមមានកិច្ចសន្យាលក់ កិច្ចសន្យាដូរ កិច្ចសន្យាអោយ ត្រូវធ្វើឡើងតាមរូបមន្តនៃលិខិតយថាភូត និងត្រូវបង់ពន្ធប្រថាប់ត្រាពីការផ្ទេរ ។ លិខិតសញ្ញាទាំងនេះ ជាលិខិតផ្លូវការ មានតម្លៃពេញលេញតាមផ្លូវច្បាប់ដែលត្រូវតំកល់ទុកយ៉ាងប្រុងប្រយ័ត្ន មានរបៀប និងសុវត្ថិភាពជាទីបំផុត ។

ខ.-សេចក្តីសំរេចរបស់តុលាការ ដែលរួមមានសាលក្រម និងសាលដីកា ត្រូវតែជាច្បាប់ដើម ឬជាច្បាប់ចម្លងដោយធ្វើនីត្យានុកូលកម្ម(Légaliser) ។

គ.-លិខិតបញ្ជាក់ :

• **អំពីប្រភេទទ្រព្យ** : លិខិតបញ្ជាក់អំពីប្រភេទទ្រព្យ ជាលិខិតដែលប្រកាសដោយម្ចាស់ទ្រព្យ មានសាក្សីដឹងឮ និងបញ្ជាក់ដោយមេឃុំ ចៅសង្កាត់ ។ ក្នុងករណីម្ចាស់ទ្រព្យមានប្តី ឬប្រពន្ធ ដើម្បីក្លាយជាទ្រព្យផ្ទាល់ខ្លួន( PM ឬ PF) ចាំបាច់ត្រូវមានការទទួលស្គាល់ ឬយល់ព្រមពីសហព័ទ្ធម្ខាងទៀត ។ ទ្រព្យផ្ទាល់ខ្លួន គឺជាទ្រព្យដែលសហព័ទ្ធទទួលបាន ឬមានមុនរៀបអាពាហ៍ពិពាហ៍ និងទ្រព្យដែលសហព័ទ្ធ ទទួលបានផ្ទាល់ក្រោយរៀបអាពាហ៍ពិពាហ៍ តាមរយៈអំណោយ មរតក ឬអច្ច័យទាន ជាដើម។

• **អំពីស្ថានភាពស៊ីវិល** : លិខិតបញ្ជាក់អំពីស្ថានភាពស៊ីវិល គឺជាលិខិតចេញដោយមេឃុំ ចៅសង្កាត់ បញ្ជាក់អំពីភាពលីវ មេម៉ាយ ពោះម៉ាយ ឬមរណភាព របស់ម្ចាស់ទ្រព្យ ។ ដោយបច្ចុប្បន្ន យើងមិនទាន់កសាងសៀវភៅអត្រានុកូលដ្ឋានបានចប់សព្វគ្រប់ លិខិតបញ្ជាក់អំពីស្ថានភាពស៊ីវិលរបស់ម្ចាស់ទ្រព្យ គឺជាឯកសារសំខាន់ក្នុងការងារចុះ

បញ្ជីដីធ្លី ពិសេសទាក់ទងនឹងការកំណត់ប្រភេទទ្រព្យ ដូចជា ទ្រព្យបើរ ទ្រព្យផ្ទាល់ខ្លួនខាងប្រពន្ធ ទ្រព្យផ្ទាល់ខ្លួនខាងប្តី ទ្រព្យរួមប្តីប្រពន្ធ សហកម្មសិទ្ធិ... និងទាក់ទងនឹងទំនាក់ទំនងញាតិក្នុងការជិរះមរតក ។

• លិខិតផ្សេងៗទៀត : មានលិខិតរណបផ្សេងៗទៀត ដែលជាប្រភេទលិខិតបញ្ជាក់ដែរ ដូចជាលិខិតបញ្ជាក់អំពីអាសយដ្ឋាន ឬទីលំនៅ, លិខិតបញ្ជាក់អំពីកាលបរិច្ឆេទនៃការកាន់កាប់ដី, លិខិតស្នើកែតម្រូវ, លិខិតបញ្ជាក់អះអាងផ្សេងៗ,... ។

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ត្រូវទទួលខុសត្រូវក្នុងការកសាងឯកសារ ការត្រួតពិនិត្យសុពលភាព ភាពត្រឹមត្រូវ និងគ្រប់គ្រាន់នៃឯកសារ និងការកាន់កាប់ឯកសារសុរិយោដី ។ ឯកសារសុរិយោដី មិនត្រូវឱ្យមានការកោសលុប ឬសរសេរជ្រៀត បន្ថែម សរសេរត្រួត ឬគូសបន្ថែម បានឡើយ ។ ការកែតម្រូវក្នុងឯកសារសុរិយោដីដែលទាក់ទងនឹងកំហុសបច្ចេកទេស អាចប្រព្រឹត្តទៅបាន លុះត្រាតែមានឯកសារបញ្ជាក់ត្រឹមត្រូវ ។

ក្រសួងសង្ឃឹមយ៉ាងមុតមាំថា អស់លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុងទាំងអស់ នឹងខិតខំអនុវត្តសារាចរណែនាំនេះមានប្រសិទ្ធភាព ។ នៅពេលដែលក្រសួង កំពុងរៀបចំពិនិត្យកែលំអឯកសារទាក់ទងនឹងការផ្ទេរសិទ្ធិ ការធានា និងការបង្កើតសិទ្ធិផ្សេងៗលើក្បាលដី គំរូឯកសារគតិយុត្ត និងនីតិវិធីដែលបានអនុវត្តកន្លងមកក្នុងប្រព័ន្ធចុះបញ្ជីដីមានលក្ខណៈដាច់ដោយដុំ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងការចុះបញ្ជីដីបន្តនេះ ។

សេចក្តីណែនាំអនុវត្តនេះ មានអានុភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

**កន្លែងទទួល :**

- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី

"ដើម្បីជូនជ្រាប"

- គ្រប់អគ្គនាយកដ្ឋានក្រោមឱវាទក្រសួង
- គ្រប់មន្ទីរ ដ.ន.ស.សខេត្ត ក្រុង

"ដើម្បីអនុវត្ត"

- ឯកសារ

រដ្ឋមន្ត្រី

 អ៊ឹម ឈុនលឹម

គំរូលេខ ៧

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## តារាងស្រង់លេខប័ណ្ណសំគាល់សិទ្ធិ

(ប័ណ្ណសំគាល់សិទ្ធិកាន់កាប់ ប្រើប្រាស់ដីធ្លី និងប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ)

ដែលបានចេញកន្លងមក ក្នុងតំបន់ធ្វើការវិនិច្ឆ័យ

នៅភូមិ....... ឃុំ/សង្កាត់........ ស្រុក/ខណ្ឌ......... ខេត្ត/ក្រុង........

| ល.រ | លេខប័ណ្ណចាស់ | កាលបរិច្ឆេទប័ណ្ណ | លេខប័ណ្ណថ្មី /ក្បាលដី | កាលបរិច្ឆេទប័ណ្ណ | លេខសៀវភៅគោលបញ្ជី | ផ្សេងៗ |
|---|---|---|---|---|---|---|
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |
| | | | | | | |

.............., ថ្ងៃទី..... ខែ.......... ឆ្នាំ..........

ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម

សំណង់ និងសុរិយោដី,

គំរូលេខ ២

## ការប្រែប្រួលលក្ខណៈរូបនៃក្បាលដី

### ក.-ការប្រែប្រួលដោយការបំបែកក្បាលដី

ឧទាហរណ៍ : ក្បាលដីលេខ ២១០៧០៤០១-០០១៨ ត្រូវបានបំបែកជា ៣ក្បាលដី ។ លេខ ២១០៧០៤០១-០០១៨ ត្រូវគូសលុប ហើយជំនួសដោយលេខថ្មី ២១០៧០៤០១-០១២២ (លេខចុងក្រោយបង្អស់នៃក្បាលដីក្នុងភូមិ មុនពេលបែកក្បាលដីគឺ ២១០៧០៤០១-០១២១) ហើយក្បាលដីថ្មី ២ទៀត ត្រូវដាក់លេខបន្តគឺ ២១០៧០៤០១-០១២៣ និង ២១០៧០៤០១-០១២៤ ។




### ខ.-ការប្រែប្រួលដោយការបង្រួមក្បាលដី

ឧទាហរណ៍ : ក្បាលដីលេខ ២១០៧០៤០១-០០៣០, ក្បាលដីលេខ ២១០៧០៤០១-០០៣១, ក្បាលដីលេខ ២១០៧០៤០១-០០៤៦ និងក្បាលដីលេខ ២១០៧០៤០១-០០៤៧ ត្រូវបានបង្រួមមកក្បាលដីតែមួយ ។ ត្រូវគូសលុបលេខក្បាលដីទាំង ៤ នេះ ហើយជំនួសដោយលេខ ២១០៧០៤០១-០១២៥ (បន្តពីលេខក្បាលដីចុងក្រោយបង្អស់ក្នុងភូមិ) ។



គំរូលេខ ៣

## ផែនទីមានលក្ខណៈដាច់ដោយឡែក

ភូមិ............ ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ............ ខេត្ត/ក្រុង.............




មាត្រដ្ឋាន : ១/៤.០០០

**<u>សំគាល់</u>** :

❖ ក្បាលដីលេខ...(UPRN) -0003 ប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ

លេខ........... ចុះថ្ងៃ................

❖ ......

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ : ..................

រាជធានីភ្នំពេញ ថ្ងៃទី......ខែ..........ឆ្នាំ២០០៤

# សេចក្តីសម្រេច

## ស្តីពី

## ការបង្កើតក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤

## សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៦៩ អនក្រ.បក ចុះថ្ងៃទី ១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងការពារជាតិ
- យោងតាមសំណើរបស់ប្រធានក្រុមការងារអនុវត្តន៍គោលការណ៍សៀវភៅ ស ការពារជាតិ

## សម្រេច

**ប្រការ ១:** បង្កើតក្រុមការងារមួយឈ្មោះថា ក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤ ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. | ឯកឧត្តម ឧត្តមសេនីយ៍ឯក នាង ផាត | ជាប្រធាន |
| ២. | ឯកឧត្តម ឧត្តមសេនីយ៍ឯក ភួង ស៊ីផាន | ជាអនុប្រធាន |

| | | | |
|---|---|---|---|
| ៣. | ឯកឧត្តម ឧត្តមសេនិយឯក ជុំ ឈាង | ជាសមាជិក |
| ៤. | ឯកឧត្តម ឧត្តមសេនិយឯក ហ៊ុន ភឿង | ជាសមាជិក |
| ៥. | ឯកឧត្តម ឧត្តមសេនិយឯក ជា សារ៉ន | ជាសមាជិក |
| ៦. | ឯកឧត្តមឧត្តមសេនិយទោ ម៉េីម សុវត្ថិ | ជាសមាជិក |
| ៧. | ឯកឧត្តម ឧត្តមសេនិយទោ ផន ផេក្រា | ជាសមាជិក |
| ៨. | ឯកឧត្តម ឧត្តមសេនិយទោ លី ដេត | ជាសមាជិក |
| ៩. | ឯកឧត្តម ឧត្តមនាវីទោ សៅ សារិន | ជាសមាជិក |
| ១០. | ឯកឧត្តម ឧត្តមសេនិយទោ គង់ មុនី | ជាសមាជិក |
| ១១. | ឯកឧត្តម ឧត្តមសេនិយទោ តេង ឈួន | ជាសមាជិក |
| ១២. | ឯកឧត្តម ឧត្តមសេនិយត្រី សួន សំណាង | ជាសមាជិកអចិន្ត្រៃយ៍ |

**ប្រការ ២:** ក្រុមការងារនេះ មានតួនាទី និងភារកិច្ចដូចខាងក្រោម:

- រៀបចំចងក្រងនយោបាយការពារជាតិនៃព្រះរាជាណាចក្រកម្ពុជា សំរាប់រយៈពេល ១០ឆ្នាំ តាមរយៈការបង្កើតឱ្យមានទូវឯកសារយុទ្ធសាស្ត្រមួយដែលមានឈ្មោះថា សៀវភៅ ស ការពារជាតិ ២០០៤ ។
- ប្រមូលផ្តុំ និងស្វែងរកទិន្នន័យផ្សេងៗ ដើម្បីធ្វើការចងក្រងឯកសារសៀវភៅ ស ការពារជាតិ ២០០៤ នេះ ឱ្យមានលក្ខណៈជាយុទ្ធសាស្ត្រ មានភាពប្រាកដនិយម និងឆ្លើយតបជាវិជ្ជមាន ទៅនឹងនយោបាយកែទំរង់កងទ័ពរបស់រាជរដ្ឋាភិបាល ។
- សហការឱ្យបានជិតស្និទ្ធជាមួយស្ថាប័ននានារបស់រាជរដ្ឋាភិបាល ដើម្បីស្វែងរកគោលគំនិត និងអនុសាសន៍ផ្សេងៗ ដែលជាអំណោយផលល្អ សំរាប់ដំណើរការកសាងសៀវភៅ ស ការពារជាតិ ២០០៤ នេះ ។
- បន្តសហការផ្នែកបច្ចេកទេស ជាមួយប្រទេសអូស្ត្រាលី និងបើចាំបាច់ជាមួយស្ថាប័នអន្តរជាតិនានា ដើម្បីទទួលបានបទពិសោធន៍ល្អៗបន្ថែមទៀត ។
- រៀបចំធ្វើសន្និសីទ ឬសិក្ខាសាលា ដើម្បីប្រមែប្រមូលគោលគំនិត និងវិធានការណ៍យុទ្ធសាស្ត្រផ្សេងៗ ។
- បំពេញការងារផ្សេងៗទៀតដែលចាំបាច់ នៅក្នុងការងារកសាងឯកសារយុទ្ធសាស្ត្រ សៀវភៅ សការពារជាតិ ២០០៤ នេះ ។

**ប្រការ ៣:** ក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤ មានសិទ្ធិក្នុងការអញ្ជើញសេនាធិការ ឬអ្នកតំណាងការទូតនៃបណ្តាប្រទេស ដើម្បីចូលរួមក្នុងឋានៈជាអ្នកសង្កេតការណ៍ នៅក្នុងកិច្ចប្រជុំ ឬ សិក្ខាសិលារបស់ខ្លួន ។

**ប្រការ ៤:** ក្រុមការងារសៀវភៅ ស ការពារជាតិ ២០០៤ មានសិទ្ធិប្រើប្រាស់ត្រាក្រសួងការពារជាតិ ។

**ប្រការ ៥:** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយពីសេចក្តីសំរេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦:** អគ្គមេបញ្ជាការ ខភម អគ្គនាយក អគ្គនាយកដ្ឋាន នាយកខុទ្ទកាល័យ កពជ បណ្តាកងឯកភាព ស្ថាប័នដែលមានការពាក់ព័ន្ធ និងសមាសភាពដូចប្រការ១ ត្រូវអនុវត្តសេចក្តីសំរេចនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខា និងឡាយព្រះហស្តលេខា នេះតទៅ ។

**សហរដ្ឋមន្ត្រី**

[illegible] ទៀ_បាញ់ ស៊ីសុវត្ថិ_សិរីរ័ត្ន

**ន្ញើជូន:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

  " ដើម្បីជ្រាប"
- អគ្គបញ្ជាការដ្ឋាន ខភម.
- ដូចប្រការ ១ និង៦

  " ដើម្បីអនុវត្តន៍ "

-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការពារជាតិ

លេខ : ០២៦ / ស.ស.រ / ២០០៤

រាជធានីភ្នំពេញ, ថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០០៤

# សេចក្តីសំរេច
## ស្តីពី
## ការបង្កើតផ្លាកសញ្ញាបន្ថែម សំរាប់បិទលើទោចក្រយានយន្ត កងឯកភាពកងរាជអាវុធហត្ថ

## សហរដ្ឋមន្ត្រី ក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ ០២ ន.ស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ។
- បានឃើញព្រះរាជក្រមលេខ ន.ស/រកត/០១៩៦/០៧ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការពារជាតិ ។
- បានឃើញអនុក្រឹត្យលេខ ៧៧ អនក្រ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤ ស្តីពីភារកិច្ច និងរចនាសម្ព័ន្ធទូទៅ នៃកងរាជអាវុធហត្ថ ។
- យោងអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី១១ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការកែសំរួលផ្លាកសញ្ញាឋានន្តរស័ក្តិ សញ្ញាកងឯកភាពឆ័ត្រយោង ឯកសណ្ឋានការងារលេខ៤ មួកបេរេ ការស្លៀកពាក់ឯកសណ្ឋានការងារលេខ៤ និងសញ្ញា អគ្គបញ្ជាការ កងទ័ពជើងគោក ជើងទឹក ជើងអាកាស និងរូបសញ្ញាក្រសួងការពារជាតិ ។
- យោងអនុក្រឹត្យលេខ ២៦ អនក្រ ចុះថ្ងៃទី ០៨ ខែឧសភា ឆ្នាំ១៩៩៨ ស្តីពីឯកសណ្ឋាន និង ផ្លាកសញ្ញាកងរាជអាវុធហត្ថ ។

## សំរេច

**ប្រការ១** : ត្រូវបានបង្កើតផ្លាកសញ្ញាបន្ថែមសំរាប់បិទទោចក្រយានយន្តរបស់កងឯកភាព កងរាជអាវុធហត្ថ ដូចខាងក្រោម:

**ក- រូបភាពផ្លាកសញ្ញា**

- ផ្នែកខាងលើមានចារិកអក្សរ ( កងរាជអាវុធហត្ថ ) ពណ៌ទឹកប៊ិច ។

- ផ្នែកកណ្តាលមានអក្សរកាត់ធំៗពីរតួ ពណ៌ទឹកប៊ិច ( អ.ហ ) ។
- សងខាងអក្សរ អ.ហ មានស្លាបបីថ្នាក់ ពណ៌ទឹកប៊ិច ។
- ផ្នែកខាងក្រោមមានសរសេរជាអក្សរបារាំង ហ្សង់ដាមមើរីពណ៌ទឹកប៊ិច( GENDARMIERIE ) ។

**ខ- ខ្នាត និងការប្រើប្រាស់ផ្លាកសញ្ញា**

- ខ្នាតតូច មានបណ្តោយទំហំ ២៤សម កំពស់ ៩.៧៥សម សំរាប់បិទលើធុងសាំង ។
- ខ្នាតធំ មានបណ្តោយទំហំ ៣២សម កំពស់ ១៣សម សំរាប់បិទលើរបាំងខាងមុខ ។

**ប្រការ២ :** នាយក ខុទ្ទកាល័យក្រសួងការពារជាតិ មេបញ្ជាការកងរាជអាវុធហត្ថ អង្គភាព ស្ថាប័ន ដែលមានការពាក់ព័ន្ធ ត្រូវអនុវត្តន៍សេចក្តីសំរេចនេះអោយមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខានិងឡាយព្រហស្តលេខានេះតទៅ ។

**ចម្លងជូន**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គបញ្ជាការដ្ឋាន ខ.ភ.ម
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី ✓

" **ដើម្បីជូនជ្រាប** "
- ឯកសារ-កាលប្បវត្តិ

នាយឧត្តមសេនីយ៍ ទៀ_បាញ់ ស៊ីសុវត្ថិ_សិរីរ័ត្ន

boukry 2

កងរាជអាវុធហត្ថ

ក.ហ

GENDARMERIE ROYALE

## សំរាប់បិតធុងសាំង




## សំរាប់បិតកញ្ចាក់មុខ






